**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# របាយការណ៍
## ស្តីពី
## ការបូកសរុបលទ្ធផលនៃអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
## សាលាភូមិន្ទរដ្ឋបាល ថ្ងៃទី០៩-១០ ខែមីនា ឆ្នាំ២០១៧
## ថ្លែងដោយឯកឧត្តម រស់ សុផាន់ រដ្ឋលេខាធិការក្រសួងមុខងារសារណៈ

- *សូមគោរពឯកឧត្តមកិត្តិបណ្ឌិត* ***ពេជ្រ ប៊ុនធិន*** *រដ្ឋមន្រ្តីក្រសួងមុខងារសាធារណៈ ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- *ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន ជាទីគោរព!*
- *ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ភ្ញៀវកិត្តិយស និង អង្គសន្និបាត ទាំងមូល ជាទីមេត្រី!*

ថ្ងៃនេះក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយជាអនេកប្បការ និង មានកិត្តិយសសូមស្វាគមន៍និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និង លើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ។ ក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ពីលទ្ធផលនៃអង្គសន្និបាតជូនអង្គពិធីទាំងមូលជ្រាប ដូចខាងក្រោម៖

### ១-ទិដ្ឋភាពទូទៅរបស់អង្គសន្និបាត

ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកអង្គសន្និបាតរយៈពេលពីរថ្ងៃ គិតចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ នៅសាលាភូមិន្ទរដ្ឋបាល។ អង្គសន្និបាត មានការចូលរួមពីថ្នាក់ដឹកនាំ

ក្រសួងមុខងារសាធារណៈ និង ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិករបស់ក្រសួង ស្ថាប័ននានា ភ្ញៀវកិត្តិយស និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សរុបចំនួន៣១១នាក់ ក្នុងនោះ ស្ត្រីចំនួន៧៨នាក់។

## ២-ដំណើរការនៃអង្គសន្និបាត

អង្គសន្និបាត បានធ្វើការពិភាក្សាលើប្រធានបទចំនួន១២ ដែលធ្វើបទអន្តរាគមន៍ដោយថ្នាក់ដឹកនាំក្រសួង រួមមាន (១)អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ (២)អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ (៣)អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ (៤)អគ្គាធិការដ្ឋាន (៥)នាយកដ្ឋានសវនកម្មផ្ទៃក្នុង (៦)សាលាភូមិន្ទរដ្ឋបាល (៧)ការងារយេនឌ័រ (៨)ការងារយុវជន (៩)ការគ្រប់គ្រងមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិ (១០)ការអនុវត្តការត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីគោលនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រដ្ឋាភិបាលកម្ពុជា (១១)ការងារអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង (១២)ទស្សនវិស័យនៃកំណែទម្រង់រដ្ឋបាលសាធារណៈ និងការផ្សារភ្ជាប់ជាមួយកំណែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

បទអន្តរាគមន៍នីមួយៗ ផ្តោតជាសំខាន់ទៅលើលទ្ធផលការងារដែលបានអនុវត្តរយៈពេលមួយឆ្នាំមកនេះ ព្រមទាំងលើកឡើងអំពីបញ្ហាប្រឈមដែលបានជួបប្រទះ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៧ ដែលអង្គភាពនិងក្រុមការងារនីមួយៗរបស់ក្រសួងមុខងារសាធារណៈត្រូវអនុវត្តនាពេលខាងមុខ។ បន្ទាប់ទៅនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនឯកឧត្តមកិត្តិបណ្ឌិត ព្រមទាំងអង្គសន្និបាតទាំងមូលនូវលទ្ធផលការងារសំខាន់ៗ ដែលក្រសួងមុខងារសាធារណៈសម្រេចបាន បញ្ហាប្រឈមចំបងៗ និងទិសដៅការងារឆ្នាំ២០១៧ ដូចខាងក្រោម៖

## ៣-លទ្ធផលការងារសំខាន់ៗ

ក្នុងរយៈពេលពីរថ្ងៃនៃដំណើរការអង្គសន្និបាតនេះ ក្រសួងមុខងារសាធារណៈ អាចធ្វើការបូកសរុបនូវលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

### ៣.១-ការអភិវឌ្ឍស្ថាប័ននៃក្រសួងមុខងារសាធារណៈ

លទ្ធផលសំខាន់ៗក្នុងការអភិវឌ្ឍស្ថាប័ននៃក្រសួងមុខងារសាធារណៈមានជាអាទិ៍៖

- បានដាក់ឱ្យអនុវត្តក្រុមអ្នកនាំពាក្យ ក្រុមការងារបណ្តាញទំនាក់ទំនងសង្គម (Facebook) ក្រុម Telegram ថ្នាក់ដឹកនាំក្រសួង និងនីតិវិធីនៃការផ្តល់លិខិតបញ្ជាបេសកកម្ម
- បានរៀបចំក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់ក្រសួងមុខងារសាធារណៈ និងកែសម្រួលសមាសភាពក្រុមលេខាធិការ នៃក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងមុខងារសាធារណៈ

- បានជួសជុលនិងកែលម្អអគារនិងសោភណ្ឌភាពទីស្តីការក្រសួង បន្ទប់សិក្សានៃសាលាភូមិន្ទរដ្ឋបាល និងមន្ទីរមុខងារសាធារណៈខេត្តកែប
- បានសាងសង់អគារមន្ទីរមុខងារសាធារណៈ ខេត្តកំពង់ចាម ខេត្តស្វាយរៀង និង ខេត្តរតនគិរី
- បានចុះវាស់វែងដីបំរុងទំហំ**២.៦០**ហិចតា នៅខេត្តត្បូងឃ្មុំ ដើម្បីសាងសង់សាលាបណ្តុះបណ្តាលភូមិភាគជូនមន្ត្រីរាជការស៊ីវិល
- បានជំរុញការរៀបចំចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់សាលាភូមិន្ទរដ្ឋបាល និង រៀបចំបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋកើនថយសម្រាប់ឆ្នាំ២០១៥ របស់ទីស្តីការក្រសួង
- បានចុះប្រមូលពត៌មាន និង ធ្វើសវនកម្មនៅតាមមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ព្រមទាំងបានផ្តល់អនុសាសន៍កែលម្អចំណុចខ្វះខាត ដើម្បីជានាប្រសិទ្ធភាពការងារ
- ក្រសួងបានយកចិត្តទុកដាក់អភិវឌ្ឍសមត្ថភាពនិងអាជីព របស់មន្ត្រីរាជការវ័យក្មេង តាមរយៈការផ្តល់ឱកាសឱ្យចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង នៅក្នុងនិងក្រៅប្រទេស និង ទទួលមុខតំណែងពីថ្នាក់អនុប្រធានការិយាល័យដល់ថ្នាក់អគ្គនាយកមានចំនួន**២០៩**នាក់ ស្មើនឹងចំនួន**២៦.៨០%** នៃចំនួនមន្ត្រីរាជការស៊ីវិលសរុបរបស់ក្រសួង។

## ៣.២-ការងារគ្រប់គ្រងមុខងារសាធារណៈ

លទ្ធផលសំខាន់ៗនៅក្នុងការគ្រប់គ្រងមុខងារសាធារណៈ រួមមាន៖

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តចំនួន**១៤** ដើម្បីគាំទ្រដល់សកម្មភាពការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនិងវិស័យមុខងារសាធារណៈ
- បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល នៅថ្នាក់ក្រោមជាតិចំនួន៥១លើក ដែលមានសិក្ខាកាមសរុបចំនួន**៧,៨៤១**នាក់
- បានឆ្លើយតបទៅសំណើសុំកែសម្រួលរចនាសម្ព័ន្ធចំនួន**១០**ក្រសួង ស្ថាប័ន
- បានផ្តល់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន**៧,៦៤១**កន្លែង និង ក្របខណ្ឌពិសេសចំនួន**៦,២៤១**កន្លែង
- បានបែងចែកមន្ត្រីជាប់កិច្ចសន្យាចំនួន**១៧,៦៥៩**កន្លែង ឧទ្យានុរក្សចំនួន**៩៦០**កន្លែង គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យាចំនួន**១,៤៦២**កន្លែង គ្រូកិច្ចសន្យាចំណេះដឹងទូទៅចំនួន**៦,០៨៨**កន្លែង គ្រូកិច្ចសន្យាអប់រំក្រៅប្រព័ន្ធចំនួន**២,៤៧២**កន្លែង និង គ្រូថ្នាក់ពីរវេននិងថ្នាក់គួបចំនួន**១៦,៥១៨**កន្លែង
- បានដំឡើងប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យាដល់**៤០០,០០០**រៀល

- បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យា និង ការបើកផ្តល់ប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារ
- បានស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល និង ផ្តល់ទិដ្ឋការជូនក្រសួង ស្ថាប័ន ដើម្បីអភិវឌ្ឍន៍អាជីពមន្ត្រីរាជការស៊ីវិលចំនួន**៥៧,៩៨៤**ករណី
- បានការកែតម្រូវការប្រែប្រួលស្ថានភាពរដ្ឋបាល និង គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ចំនួន**១០១,៦១៩**ករណី
- បានរកឃើញប្រាក់បៀវត្សដែលត្រូវបង្វែរចូលថវិការដ្ឋចំនួន**៥,៩១៧,៣៧៥,៩៦៩**រៀល
- បានកាត់ពន្ធលើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលចំនួន**១២,៧៤៧,៩៨៦,០៧០**រៀល
- បាន (១)បញ្ចូលទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធបណ្ណសារចំនួន**៨៣១៩**នាក់ (២)រៀបចំសលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលឡើងវិញចំនួន**៥៦,២៣៦**នាក់ (៣)សរសេរសលាកប័ត្រព័ត៌មានមន្ត្រីរាជការ លើស្រោមសំណុំលិខិតបានចំនួន **៦៥,៧៤៩**នាក់ និង (៤)ធ្វើសេចក្តីជូនដំណឹងស្តីពីការផ្តល់ទិន្នន័យមន្ត្រីរាជការ ចូលនិវត្តន៍តាមកាលកំណត់ចំនួន**១,១៩៧**នាក់ និង មុនកាលកំណត់ចំនួន**៧៧**នាក់
- បានចុះធ្វើអធិការកិច្ច ស្រាវជ្រាវ និង ដោះស្រាយករណីមិនប្រក្រតីរបស់មន្ត្រីរាជការ ស៊ីវិលចំនួន**៤៥**ករណី រកឃើញប្រាក់បៀវត្សបើកលើសចំនួន**២០៣,៧៨៣,៩៦៤**រៀល ហើយចាត់វិធានការឱ្យបង្វែរថវិកាចូលរតនាគារខេត្តចំនួន**៥៤,៦៦៦,៣៣០**រៀល និងស្នើសុំឱ្យលុបឈ្មោះចេញពីក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន០១ករណី
- បានអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ២០១៤-២០១៨ ដែលនាំឱ្យចំនួនស្ត្រីជាមន្ត្រីរាជការបានកើនដល់**៤0%** និង ចំនួនស្ត្រីក្នុងមុខដំណែង ចាប់ពីថ្នាក់ការិយាល័យដល់ថ្នាក់អគ្គនាយកកើនដល់**២២%**
- បានដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យស្តីពី "លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាល ថ្នាក់ក្រោមជាតិ" និង បានផ្សព្វផ្សាយព្រះរាជក្រឹត្យនេះនៅ២៣រាជធានីខេត្ត ព្រមទាំង ផ្សព្វផ្សាយគោលនយោបាយ និង លិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ ស៊ីវិលនៅថ្នាក់ក្រោមជាតិជូនរាជធានី ខេត្ត
- បានរៀបចំសេចក្តីណែនាំស្តីពីបែបបទ និង នីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាល ថ្នាក់ក្រោមជាតិ
- បានអនុវត្តផែនការសកម្មភាព នៃកិច្ចសហប្រតិបត្តិការមុខងារសាធារណៈអាស៊ាន និងអាស៊ានបូកបី ចូលរួមកិច្ចប្រជុំនិងចែករំលែកបទពិសោធន៍របស់កម្ពុជាក្នុងក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យមុខងារសាធារណៈ លើកទី១៨ នៅប្រទេស ហ្វីលីពីន។

## ៣.៣-ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ដែលផ្តោតជាសំខាន់លើ (១)ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២)ការអភិវឌ្ឍសមត្ថភាព ការកែលម្អការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និង (៣)ការកែទម្រង់ប្រព័ន្ធបៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់មន្ត្រីរាជការ។ ជាមួយគ្នានេះ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានដាក់ឱ្យអនុវត្តឯកសារគោលការណ៍ណែនាំ ស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ និង បានស្នើសុំឱ្យក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ បានចំនួន២៣ក្រសួង ស្ថាប័ន និង ២៥ រាជធានី ខេត្ត។

### ៣.៣.១-ការកែលម្អសេវាសាធារណៈ

- បានសហការជាមួយក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍ ដើម្បីដាក់ឱ្យអនុវត្តកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈ តាមរយៈទូរស័ព្ទស្មាតហ្វូន
- បានធ្វើសុក្រិត្យភាពលើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈចំនួន២៦ក្រសួង ស្ថាប័ន
- បានដាក់ឱ្យអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេសនៅក្រសួងសុខាភិបាល ចំនួន០៤បន្ថែមទៀត រួមមាន មន្ទីរពេទ្យបង្អែកខេត្តកំពត ខេត្តព្រៃវែង ខេត្តក្រចេះ និងខេត្តកំពង់ធំ
- បានចុះសិក្សាពីការផ្តល់សេវាចេញវិញ្ញាបនបត្រប្រភពដើមទំនិញ ចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក ផ្តល់លិខិតអនុញ្ញាតច្បាប់ប្រកបអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្ម ផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈធាតុត្បូងថ្មមានតម្លៃ នៅអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម និង មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង និង (២)សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស នៅក្រសួងយុត្តិធម៌
- បានចុះសិក្សាពីការផ្តល់សេវាសាធារណៈ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ ខេត្តកំពត ខេត្តសៀមរាប និងរាជធានីភ្នំពេញ ដោយផ្តោតលើសេវាសុរិយោដីនិងភូមិសាស្ត្រ និង សេវាសំណង់
- បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ និង សេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យដំណើរការច្រកចេញចូលតែមួយរបស់ក្រសួងមុខងារសាធារណៈ។

### ៣.៣.២-ការកសាងនិងការអភិវឌ្ឍធនធានមនុស្ស

- បានដាក់ឱ្យអនុវត្តឯកសារណែនាំស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល"

- បានរៀបចំតារាងពិពណ៌នាមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានរៀបចំរបាយការណ៍សិក្សាលើមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានចុះស្រង់ទិន្នន័យនិងបូកសរុបរបាយការណ៍មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីឧទ្យានុរក្សរបស់ក្រសួងបរិស្ថាន
- បានបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ ចំនួន **៥៦នាក់ (ស្ត្រី១១នាក់)**
- បានបណ្តុះបណ្តាលវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ ដែលមានសិក្ខាកាមចំនួន **៣៧៨នាក់ (ស្ត្រី៣៩នាក់)**
- បានបណ្តុះបណ្តាលវគ្គវិក្រឹត្យការមន្ត្រីមធ្យម ដែលមានសិក្ខាកាមចំនួន **១២៤នាក់ (ស្ត្រី១១នាក់)**
- បានបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថាន ដែលមានសិក្ខាកាមចំនួន **២០នាក់ (ស្ត្រី០៦នាក់)**
- បានបណ្តុះបណ្តាលថ្នាក់ដឹកនាំជាស្ត្រីឋានៈរដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការដែលមានសិក្ខាកាមចំនួន**៨៤នាក់**
- បានបណ្តុះបណ្តាលស្តីពី "ការជំរុញកំណែទម្រង់អភិបាលកិច្ចល្អសម្រាប់មន្ត្រីរាជការជាន់ខ្ពស់" ដែលមានសិក្ខាកាមសរុបចំនួន១៧០នាក់ (ស្ត្រី១៥នាក់) ដើម្បីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំកម្រិតអគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

### ៣.៣.៣-ការកែទម្រង់ប្រព័ន្ធបៀវត្ស

**បានរៀបចំ និង ដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងកែលម្អប្រព័ន្ធលាភការរបស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ** រួមមាន (១)អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា (២)អនុក្រឹត្យស្តីពីការកែសម្រួល និង ការដំឡើងប្រាក់បំណាច់មុខងារជូនយោធិន នៃកងយោធពលខេមរភូមិន្ទ (៣)អនុក្រឹត្យស្តីពីការកែសម្រួល និង ការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីនគរបាលជាតិ (៤)អនុក្រឹត្យស្តីពីប្រាក់បំណាច់មុខងារចៅក្រមនិងព្រះរាជអាជ្ញា (៥)អនុក្រឹត្យស្តីពីការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (៦)អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល (៧)អនុក្រឹត្យការបន្ថែមរបប

សន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន (៨)អនុក្រឹត្យស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំរកា អដ្ឋស័ក ពុទ្ធសករាជ ២៥៦០ (៩)អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និង មន្ត្រីជាប់កិច្ចសន្យា (១០)អនុក្រឹត្យស្តីពីការកែសម្រួល និង ការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ (១១)អនុក្រឹត្យស្តីពីការបន្ថែមប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ (១២)អនុក្រឹត្យស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា (១៣)អនុក្រឹត្យស្តីពីការដំឡើងប្រាក់វិភាជន៍គ្រួសាររបស់មន្ត្រីរាជការស៊ីវិល ប្រាក់បំណាច់ឧបត្ថម្ភគ្រួសារនិងកូនយោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ (១៤)អនុក្រឹត្យស្តីពីការកែប្រែតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និង (១៥)សេចក្តីជូនដំណឹងស្តីពីការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៦។

### ៣.៣.៤-ការងារសម្របសម្រួលការកែទម្រង់អន្តរវិស័យ

**លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានដាក់ចេញនូវផែនការសកម្មភាពចំនួន០៩** ដែលត្រូវអនុវត្តរួមគ្នាក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងកំណែទម្រង់ទាំងបី រួមមាន (១)ពង្រឹងការបើកផ្តល់បៀវត្សនិងប្រាក់លាភការផ្សេងៗទៀតតាមប្រព័ន្ធធនាគារ ឬ តាមប្រព័ន្ធ e-Transfer (២)រៀបចំក្របខណ្ឌ និងយន្តការអនុវត្តទណ្ឌកម្មចំពោះការគ្រប់គ្រងធនធានសាធារណៈ (៣)កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យមានសមានគតិភាពជាមួយនឹងប្រព័ន្ធដំណើរការការថ្មីដែលរួមមានផ្នែករដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ និងបច្ចេកទេសទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ (៤)ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួងស្ថាប័ន ដើម្បីធានាសុខដុមនីយកម្ម (៥)បង្កើតគុណភាពលើការកសាងសមត្ថភាព និងការបណ្តុះបណ្តាលទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ (៦)រៀបចំក្របខណ្ឌរួមនៃការគ្រប់គ្រង និង បែងចែកប្រាក់រង្វាន់ពីចំណូលមិនមែនសារពើពន្ធប្រកបដោយសមធម៌ និងប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ (៧)រៀបចំនិងដាក់ឱ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និង បណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវានៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ (៨)រៀបចំ និង ដាក់ឱ្យអនុវត្តក្របខណ្ឌវិមជ្ឈការហិរញ្ញវត្ថុ (គោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម ការអនុវត្តការប្រមូលចំណូលផ្ទាល់ ឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំស្តីពីផែនការ

យុទ្ធសាស្ត្រថវិកា ការផ្ទេរធនធានមានភ្ជាប់លក្ខខ័ណ្ឌ ថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា) និង (៩)រៀបចំនិងដាក់ឱ្យអនុវត្តយន្តការស្ថាប័នគាំទ្រភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ ការលើកទឹកចិត្តលើការកែទម្រង់។

## ៤-បញ្ហាប្រឈមដែលបានជួបប្រទះ

ក្រសួងមុខងារសាធារណៈ ជួបប្រទះនូវបញ្ហាប្រឈមចំបងៗ ដូចខាងក្រោម៖

១. សមត្ថភាពស្ថាប័ននិងធនធានមនុស្សរបស់ក្រសួង នៅមិនទាន់អាចឆ្លើយតបបានពេញលេញទៅនឹងសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល

២. ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងមធ្យោបាយអនុវត្តការងារនៅមានកម្រិត

៣. ការកសាងសមត្ថភាពមន្ត្រីរាជការស៊ីវិល ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល មិនទាន់មានលក្ខណៈជាប្រព័ន្ធ និងឆ្លើយតបទៅនឹងការវិវឌ្ឍរបស់រដ្ឋបាលសាធារណៈ

៤. ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនិងការលើកកម្ពស់គុណភាពសេវាសាធារណៈ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) មិនទាន់កំណត់ច្បាស់លាស់

៥. ការផ្សារភ្ជាប់ផ្នែកស្ថាប័ន និង សកម្មភាពកែទម្រង់ទាំងឡាយក្នុងក្របខណ្ឌរាជរដ្ឋាភិបាលនៅមិនទាន់អនុវត្តឱ្យបានពេញលេញនិងមានប្រសិទ្ធភាព

៦. ការធ្វើសកម្មភាពរបស់គណៈកម្មាធិការកំណែទម្រង់រដ្ឋបាលនៅគ្រប់ថ្នាក់ គ្រប់ផ្នែកនៅមានកម្រិត

៧. ការយល់ដឹងអំពីអាស៊ាន ព្រមទាំងការអនុវត្តផែនការការងារ នៃកិច្ចសហប្រតិបត្តិការអាស៊ាន ស្តីពីកិច្ចការមុខងារសាធារណៈ នៅមានកម្រិតមិនទាន់អាចឆ្លើយតបទៅនឹងបរិបទអាស៊ាន។

## ៥-ទិសដៅអនុវត្តការងារឆ្នាំ២០១៧

បន្ថែមលើការអនុវត្តមុខងារ និងបេសកកម្មជាប្រចាំរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាព ព្រមជាមួយការអនុវត្តបន្តដើម្បីពង្រឹងនិងពង្រីកនូវសមិទ្ធផលការងារ ដែលសម្រេចបានកន្លងមក ក្រសួងមុខងារសាធារណៈ បានដាក់ចេញនូវទិសដៅការងារជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៧ ដូចខាងក្រោម៖

- បន្តសិក្សាស្រាវជ្រាវឯកសារលិខិតបទដ្ឋានផ្សេងៗ និង រៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បន្តទទួលពាក្យបណ្តឹង និង អង្កេតស្រាវជ្រាវពាក់ព័ន្ធនឹងវិវាទមុខងារសាធារណៈ និងបន្តចុះធ្វើអធិការកិច្ចអំពីភាពមិនប្រក្រតីក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បន្តអនុវត្តផែនការសកម្មភាព (ផ.អ.III) ដំណាក់កាលទី២ (២០១៥-២០១៧) នៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ នៅថ្នាក់ក្រោមជាតិ
- រៀបចំនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនៅតាមខេត្តនានា
- បន្តពិនិត្យ និង ដោះស្រាយសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ការប្រើប្រាស់ក្របខណ្ឌមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្ដែត
- បន្តធ្វើសមទិន្នព័ត៌មានទៅក្នុងសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិល
- បន្តអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨
- បន្តជ្រើសរើសសិស្សក្រមការជំនាន់ទី៧ ចំនួន១២០នាក់ និង សិស្សជាន់ខ្ពស់ជំនាន់ទី១០ ចំនួន៦០នាក់ វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ចំនួន២៨០នាក់ និង វគ្គវិក្រឹត្យការមន្ត្រីមធ្យមចំនួន១០០នាក់
- បន្តធ្វើការបណ្ដុះបណ្ដាលដល់មន្ត្រីថ្មីចំនួន២៤០នាក់
- បន្តបើកវគ្គបណ្ដុះបណ្ដាលបន្តសម្រាប់មន្ត្រីរាជការ ជាគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សានៅក្នុងរាជធានីភ្នំពេញចំនួន២៨៥នាក់
- បន្តបើកវគ្គបណ្ដុះបណ្ដាលសម្រាប់អភិបាលរងរាជធានី ខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ សិក្ខាកាមសរុបចំនួន៣៦០នាក់
- បន្តបើកវគ្គបណ្ដុះបណ្ដាលសម្រាប់អគ្គនាយករង និងប្រធាននាយកដ្ឋាននៃក្រសួង ស្ថាប័ន សិក្ខាកាមសរុបចំនួន២៤០នាក់
- បន្តចុះតាមដាន និង ត្រួតពិនិត្យការអនុវត្តលើអនុក្រឹត្យស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- បន្តធ្វើការវិភាគមុខងារនិងរចនាសម្ព័ន្ធ ព្រមទាំងការប្រើប្រាស់ធនធានមនុស្សរបស់ក្រសួង ស្ថាប័នសំខាន់ៗ មួយចំនួននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ត្រៀមរៀបចំដំឡើងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល
- រៀបចំបង្កើតកម្មវិធី និង ដាក់ឱ្យដំណើរការកាត់ពន្ធបៀវត្ស របស់ស្ថាប័ននីតិបញ្ញត្តិនិងស្ថាប័នឯករាជ្យ
- បន្តធ្វើការវិភាគមុខងារ និង រំហូរការងារសម្រាប់សេវាសាធារណៈដែលមានផលប៉ះពាល់ដោយផ្ទាល់លើជីវភាពប្រចាំថ្ងៃ របស់មន្ត្រីរាជការនិងប្រជាពលរដ្ឋ ដូចជា

ការបើកផ្តល់ប្រាក់បេសកកម្មដល់មន្ត្រីរាជការ ការផ្តល់ប្រាក់ឧបត្ថម្ភនិងប្រាក់សោធននិវត្តន៍ដល់និវត្តជន ការចុះបញ្ជីយានយន្ត ការចុះបញ្ជីដីធ្លី ការចុះអាជីវកម្ម ការផ្តល់អាជ្ញាបណ្ណសាងសង់ ការផ្តល់សំបុត្រអត្រានុកូលដ្ឋាន អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែន ជាដើម។

## ៦-វេទិកាសំណួរ ចម្លើយ និងចំណាប់អារម្មណ៍

បន្ទាប់ថ្នាក់ដឹកនាំក្រសួង និង ប្រធានអង្គភាពបានធ្វើបទអន្តរាគមន៍រួចមក សមាជិក សមាជិកា នៃអង្គសន្និបាត បានលើកជាសំណួរនិងសំណូមពរសំខាន់ៗ ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីផ្តល់អនុសាសន៍ណែនាំ ដូចខាងក្រោមៈ

- ស្នើសុំធ្វើការកែលម្អនីតិវិធី ដើម្បីឱ្យមន្ត្រីរាជការក្របខណ្ឌថ្មីទទួលប្រាក់បៀវត្សបានឆាប់រហ័ស
- ស្នើសុំឱ្យមានការអញ្ជើញ "**អភិបាលរងរាជធានី ខេត្ត**" ទទួលបន្ទុកកិច្ចការមុខងារសាធារណៈ ដើម្បីចូលរួមក្នុងអង្គសន្និបាតក្រសួងសម្រាប់ឆ្នាំក្រោយ និង ឆ្នាំបន្តបន្ទាប់ទៀត
- សំណូមពរឱ្យក្រសួងរៀបចំសន្និបាត ដោយកំណត់យកតែប្រធានបទសំខាន់ៗមកធ្វើបទអន្តរាគមន៍ រួចដាក់ជូនអង្គសន្និបាតធ្វើការពិភាក្សាស្វែងរកដំណោះស្រាយនានា កំណត់បញ្ហាអាទិភាព និងលើកទិសដៅការងារសម្រាប់ឆ្នាំក្រោយៗទៀត
- ស្នើសុំកុំដាក់កម្មវិធីសំណួរចម្លើយនៅចុងម៉ោង ជាពិសេសនៅពេលរសៀល។

– *ឯកឧត្តមកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាទីគោរពដ៏ខ្ពង់ខ្ពស់*
– *ឯកឧត្តម លោកជំទាវ និងអង្គសន្និបាតទាំងមូល ជាទីមេត្រី!*

ជារួមក្នុងរយៈពេលមួយឆ្នាំ ក្រសួងមុខងារសាធារណៈ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល លើការងារគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍន៍វិស័យមុខងារសាធារណៈ និងកែទម្រង់រដ្ឋបាលសាធារណៈឱ្យសម្រេចបានទិសដៅកែទម្រង់ទាំងបី ដែលបានដាក់ចេញនៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨ ដែលរួមមាន (១)ការកែលម្អសេវាសាធារណៈ (២)ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និង(៣)ការកែទម្រង់ប្រព័ន្ធបៀវត្ស។ ទាំងនេះស្តែងចេញឱ្យឃើញពីការប្តេជ្ញាចិត្តនិងការខិតខំប្រឹងប្រែងរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងមុខងារសាធារណៈ ដើម្បីរួមចំណែកក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាឱ្យទទួលបានជោគជ័យ។

ក្រសួងមុខងារសាធារណៈ នឹងបន្តអនុវត្តមុខងារ និង បេសកកម្មរបស់ខ្លួន ឈរលើស្មារតីម៉ឺងម៉ាត់ ហ្មត់ចត់ ឆន្ទៈមុះមុត និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលនយោបាយ

របស់រាជរដ្ឋាភិបាលនិងទិសដៅការងារជាយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៧ និង ឆ្នាំបន្តបន្ទាប់ឱ្យបានខ្ជាប់ខ្ជួន ឈានទៅសម្រេចសមិទ្ធផលថ្មីៗបន្ថែមទៀត ដើម្បីរួមចំណែកដល់ការជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។

ជាទីបញ្ចប់ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មីប្រោសប្រទានពរជ័យបវរមហាប្រសើរជូនឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាកិច្ចបន្ត ខ្ញុំបាទមានកិត្តិយសសូមគោរពអញ្ជើញឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ មេត្តាឡើងថ្លែងសុន្ទរកថាបិទអង្គសន្និបាត។

**សូមគោរពអញ្ជើញ! សូមអរគុណ!**